**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# របាយការណ៍
# ស្តីពី
# ការទទួលបានយុត្តិធម៌សម្រាប់កុមារ

ឆ្លើយតបទៅនឹងវាក្យខ័ណ្ឌទី៥៧ នៃសេចក្តីសម្រេចលេខ២២/៣២ លើប្រធានបទស្តីពី
"**ការទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុតរបស់កុមារ**"

ខែតុលា ឆ្នាំ២០១៣

រៀបចំដោយៈ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## សេចក្ដីផ្ដើម

ការិយាល័យឧត្ដមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានស្នើឱ្យព្រះរាជាណាចក្រកម្ពុជា ផ្ដល់នូវព័ត៌មានទាក់ទងទៅនឹង "សិទ្ធិទទួលបានយុត្តិធម៌សម្រាប់កុមារ" ដែលជាផ្នែកមួយនៃសេចក្ដីសម្រេចលេខ២២/៣២ លើប្រធានបទ "សិទ្ធិទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុតរបស់កុមារ"។ របាយការណ៍សង្ខេបនេះ ផ្ដល់នូវព័ត៌មានថ្មីៗបំផុតពាក់ព័ន្ធទៅនឹងបញ្ហានេះ។

គួរឱ្យកត់សម្គាល់ថា កម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារក្នុងឆ្នាំ១៩៩២ និងអនុសញ្ញា សន្ធិសញ្ញា និងពិធីសារពាក់ព័ន្ធទៅនឹងកុមារជាច្រើនទៀត។ កម្ពុជាបាននិងកំពុងចាត់វិធានការចាំបាច់មួយចំនួន ដើម្បីធានាសម្រេចឱ្យបានពេញលេញនូវសិទ្ធិកុមារ ហើយកុមារទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពរាងកាយនិងផ្លូវចិត្ត។ បន្ថែមពីលើរដ្ឋធម្មនុញ្ញរបស់ខ្លួនដែលផ្ដល់ការគាំទ្រដល់សិទ្ធិកុមារ កម្ពុជាបានអនុម័ត និង/ឬបានដាក់ឱ្យអនុវត្តនូវច្បាប់ ក្របខ័ណ្ឌច្បាប់ គោលនយោបាយ កម្មវិធី និងយន្តការមួយចំនួន ដើម្បីការពារ និងលើកកម្ពស់សិទ្ធិកុមារ។ កិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់មួយចំនួនត្រូវបានធ្វើឡើង ដើម្បីធានាឱ្យទទួលបានយុត្តិធម៌សម្រាប់កុមារ ថ្វីបើនៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនក៏ដោយ។ ខាងក្រោមនេះ ជាការបង្ហាញដោយសង្ខេបពីស្ថានភាព និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ។

### ក. នីតិវិធី និងយន្តការនានានៃយុត្តិធម៌កុមារមេត្រី ដែលស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី និងច្បាប់រដ្ឋបាល

១. ប្រទេសកម្ពុជាចាប់ផ្ដើមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណីត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់ជាបន្តបន្ទាប់។ ក្រមទាំងនេះ បានគិតគូរដល់ការចូលរួមរបស់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌។ ក្រមទាំងនោះមានបទប្បញ្ញត្តិមួយចំនួន ដែលបានកំណត់នូវយន្តការ និងនីតិវិធីយុត្តិធម៌កុមារមេត្រី។ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មានបទប្បញ្ញត្តិមួយចំនួនសម្រាប់ដំណើរការបណ្ដឹងរបស់កុមារ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មានមាត្រាមួយចំនួនពាក់ព័ន្ធនឹងការកម្រិតកំណត់សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់កុមារ សិទ្ធិក្នុងការលុបចោលសកម្មភាពរបស់អនីតិជន សិទ្ធិរបស់អនីតិជនក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងប្រកបអាជីវកម្មលក្ខខណ្ឌនៃអត្តាធីនភាព និងកិច្ចសន្យាការងាររបស់អនីតិជន។ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ចូលបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការឃាត់ខ្លួនកុមារ

ការឃុំខ្លួនបណ្តោះអាសន្ន ការរួចខ្លួនពីការបង្ខំដល់រូបរាងកាយ តំណាងផ្លូវច្បាប់ និងសេវាបកប្រែ។ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ រួមបញ្ចូលនូវបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធជាមួយនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ វិធានការ ដែលអាចអនុវត្តបានសម្រាប់កុមារ មូលទោសដែលអាចអនុវត្តបានសម្រាប់កុមារដែលមានអាយុ១៨ឆ្នាំឡើងទៅ ទោសការងារសហគមន៍សម្រាប់កុមារ ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ការទទួលផលប្រយោជន៍នៃស្ថានទម្ងន់ទោសសម្រាប់កុមារ កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង និងលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជន ក្នុងពន្ធនាគារ។

២. កម្ពុជាកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ដោយដាក់ចេញនូវវិសាលភាព និងយន្តការនីតិវិធី ដើម្បីដោះស្រាយអនីតិជនតាមរបៀបដែលមានលក្ខណៈកុមារមេត្រី និងដើម្បីការពារឱ្យបានពេញលេញនូវសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។ ច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១ ស្នើឱ្យមានការប្រព្រឹត្តជាពិសេសចំពោះជនជាប់ឃុំជាកុមារ។ ច្បាប់បញ្ជាក់ថា គ្រប់ពន្ធនាគារទាំងអស់ត្រូវមានកំណត់ត្រានៃជនជាប់ឃុំជាកុមារដាច់ដោយឡែក ហើយកុមារគ្រប់រូបត្រូវបានឃុំខ្លួនដាច់ដោយឡែកពីមនុស្សពេញវ័យ និងត្រូវបានវាយតម្លៃឱ្យបានត្រឹមត្រូវមុនពេលឱ្យធ្វើការងារពលកម្ម។ ច្បាប់ក៏ហាមឃាត់ផងដែរនូវរាល់ទម្រង់ទាំងអស់នៃការដាក់ដាក់ទណ្ឌកម្មរូបរាងកាយ។

## ខ. ឧបសគ្គ ឬកត្តារាំងស្ទះដល់កុមារក្នុងការទទួលបានយុត្តិធម៌

៣. ថ្វីបើមានការរីកចម្រើនច្រើនក៏ដោយ ក៏កម្មវិធីយុត្តិធម៌កុមារមិនទាន់ដំណើរការបានដោយខ្លួនឯងទេ គឺត្រូវបានលើកទឹកចិត្ត/ជំរុញដោយម្ចាស់ជំនួយ ហើយការព្យាយាមមួយចំនួនត្រូវបានអនុវត្ត ដើម្បីបញ្ជ្រាបកម្មវិធីនេះទៅក្នុងក្របខ័ណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ និងតាមរយៈអភិបាលកិច្ចដ៏ទូលំទូលាយ និងកិច្ចខិតខំប្រឹងប្រែងក្នុងការគោរពច្បាប់។ ការពិនិត្យតាមដាន និងការពង្រឹងយន្តការច្បាប់ដែលមានស្រាប់ ដែលការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌ ដូចជាជនប្រព្រឹត្តបទល្មើសដែលត្រូវបានចោទ ជនរងគ្រោះ និងសាក្សី គឺស្ថិតនៅដំណាក់កាលដំបូងនៅឡើយ។ ការសម្រេចចុងក្រោយ និងការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន នឹងជួយពន្លឿនដំណើរការយុត្តិធម៌សម្រាប់របៀបវារៈកុមារ។ ការពន្យារពេលការអនុម័តច្បាប់យុត្តិធម៌កុមាររបស់រដ្ឋាភិបាលបានពន្យារដល់ការបង្កើតគំរូនៃការបង្វែរ ជម្រើសចំពោះការឃុំខ្លួន និងការស្តារយុត្តិធម៌សម្រាប់កុមារ ដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់។ លុះត្រាតែច្បាប់ត្រូវបានអនុម័ត នីតិវិធីទូទៅសម្រាប់មនុស្សពេញវ័យត្រូវបានអនុវត្ត

ដោយស្វ័យប្រវត្តិចំពោះករណីនានារបស់កុមារ។ នៅពេលដែលគ្មានប្រព័ន្ធយុត្តិធម៌អនីតិជននៅកម្ពុជា ប្រព័ន្ធបច្ចុប្បន្នមិនបានពិចារណាពីតម្រូវការ និងឧត្តមប្រយោជន៍របស់កុមារ ឬដោះស្រាយឬសគល់នៃបទល្មើស និងផលវិបាករបស់កុមារម្នាក់ៗដែលពាក់ព័ន្ធនោះឡើយ។ មិនមានតុលាការកុមារ ចៅក្រម និងព្រះរាជអាជ្ញាដែលមានជំនាញឯកទេសផ្នែកសិទ្ធិកុមារទេ។

៤. ប្រព័ន្ធយុត្តិធម៌របស់កម្ពុជា នៅមិនទាន់មានមន្ត្រីគ្រប់គ្រាន់ ខ្វះធនធាន និងមិនទាន់បានបំពាក់ឧបករណ៍ឱ្យបានសមស្របនៅឡើយ ដើម្បីឆ្លើយតបទៅនឹងករណីនានាស្របទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ។ ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងវិក្រឹត្យការវិជ្ជាជីវៈមេធាវី និងការធ្វើឱ្យប្រសើរឡើងនូវអ្នកជំនាញផ្នែកច្បាប់ដែលស្ថិតនៅក្រោមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១១ និងស្ថិតក្រោមរាជបណ្ឌិតវិជ្ជាជីវៈតុលាការកាលពីឆ្នាំ២០០៦ ក្រុមមេធាវី ចៅក្រម និងព្រះរាជអាជ្ញាថ្មីត្រូវបានបង្កើតឡើង ហើយសមត្ថភាពរបស់ពួកគេកំពុងប្រសើរឡើងជាបណ្ដើរៗ។ ដោយមានចៅក្រម និងព្រះរាជអាជ្ញាផ្លូវការប្រមាណ២៨០នាក់ និងមេធាវី ដែលកំពុងធ្វើការងារប្រមាណ៥០០នាក់នៅកម្ពុជា កំពុងបម្រើប្រជាជន១៣.៨លាននាក់ ប្រព័ន្ធយុត្តិធម៌មិនទាន់មានលទ្ធភាពពេញលេញនៅឡើយដើម្បីផ្ដល់នូវមធ្យោបាយតាមផ្លូវច្បាប់ឱ្យបានរហ័ស និងប្រកបដោយប្រសិទ្ធភាព ចំពោះការរំលោភសិទ្ធិកុមារ។

៥. ខណៈដែលរដ្ឋាភិបាលមិនទាន់មានលទ្ធភាពពេញលេញនៅឡើយ ក្នុងការផ្ដល់ជំនួយផ្លូវច្បាប់ដែលមានលក្ខណៈទូលំទូលាយដល់ជនក្រីក្រ និងជាយរងគ្រោះ ការការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌ តែងតែទុកឱ្យអង្គការជំនួយផ្នែកច្បាប់ ដែលនៅខ្វះធនធាន និងមិនទាន់មានបុគ្គលិកគ្រប់គ្រាន់នៅឡើយដោះស្រាយ។ គិតត្រឹមឆ្នាំ២០១០ មានមេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាលប្រមាណ៨០នាក់ កំពុងផ្ដល់សេវាផ្នែកច្បាប់ពេញម៉ោង ដល់ក្រុមជនងាយរងគ្រោះនានា នៅទូទាំងប្រទេស។ កុមារភាគច្រើនមិនបានជួបមេធាវីរបស់ខ្លួនមុនពេលជំនុំជម្រះក្ដី ខណៈតុលាការមិនបានជូនដំណឹង ឬគ្រាន់តែចាត់តាំងមេធាវីមួយថ្ងៃមុនពេលជំនុំជម្រះក្ដីប៉ុណ្ណោះ។

៦. រយៈពេលកន្លងមកថ្មីៗនេះ ប្រព័ន្ធយុត្តិធម៌ត្រូវបានពង្រឹង តាមរយៈច្បាប់សំខាន់ៗដូចជាក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ។ ច្បាប់ពាក់ព័ន្ធនានា ដូចជាច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០ ក៏ត្រូវបានអនុម័តផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បទដ្ឋានគតិយុត្តសំខាន់ៗដទៃ

ទៀតដែលចាំបាច់សម្រាប់ដំណើរការឱ្យមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ជាអាទិ៍ ច្បាប់ស្តីពីស្ថាប័នតុលាការ លក្ខន្តិកៈនៃអង្គចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីវិសោធនកម្មមុខងារ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និងច្បាប់ស្តីពីនគរបាល កំពុងត្រូវបានរៀបចំនៅឡើយ។

៧. សមត្ថភាពនៃមន្ត្រីយុត្តិធម៌ភាគច្រើន ក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់ថ្មី និងដែលមានស្រាប់ ជាទូទៅនៅទន់ខ្សោយនៅឡើយ។ នគរបាល ចៅក្រម និងព្រះរាជអាជ្ញា កម្រពិចារណាដល់ជម្រើសក្រៅការដកហូតសេរីភាព ថ្វីបើច្បាប់ជាតិដែលមានស្រាប់ អនុញ្ញាតឱ្យមានប្រាក់ធានាក្រៅឃុំ ការដោះលែងដោយមានលក្ខខណ្ឌ និងសាលក្រមព្យួរទោសក៏ដោយ។ តួនាទីរបស់អ្នកធ្វើការងារសង្គមកិច្ច ដូចជាអ្នកគ្រប់គ្រងករណី និងអ្នកផ្តល់កិច្ចគាំទ្រដល់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ មិនទាន់ត្រូវបានទទួលស្គាល់នៅឡើយ។ កិច្ចសហការរវាងមន្ត្រីយុត្តិធម៌សំខាន់ៗ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ ដែលនាំឱ្យសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ មិនទាន់ត្រូវបានបង្ហាញឱ្យបានច្បាស់លាស់នៅក្នុងដំណើរការតុលាការ។

៨. ការប្រឈមសំខាន់ៗដទៃទៀត មានជាអាទិ៍៖ (១)ការសម្របសម្រួលដែលមានកម្រិតរវាងខេត្តនានា ក្នុងការពង្រឹងការពិនិត្យតាមដាន និងការពន្យារពេលនៃការបញ្ជូនដំណើរការដោះស្រាយករណីកុមារនៅថ្នាក់ក្រោមជាតិ និងការតាមដានលទ្ធផលកុមារពាក់ព័ន្ធវិស័យនានា (២)គ្មានគោលនយោបាយ ឬយុទ្ធសាស្ត្រជាតិស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ (៣)សេចក្តីត្រូវការឱ្យមានការរៀបចំរបាយការណ៍ទិន្នន័យ ដែលមានលក្ខណៈទូលំទូលាយ និងមានប្រសិទ្ធភាព ការតវ៉ា និងយន្តការពិនិត្យតាមដាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៤)វិធីសាស្ត្រដោះស្រាយពហុវិស័យស្តីពីការអនុវត្តនីតិវិធីកុមារមេត្រីដែលអាចប្រើប្រាស់បាននៅមានកម្រិតនៅឡើយ នៅក្នុងប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធទៅនឹងចៅក្រម ព្រះរាជអាជ្ញា នគរបាល មេធាវី និងអ្នកធ្វើការងារសង្គមកិច្ច និង (៥)ធនធាននៅមានកម្រិតក្នុងការពង្រឹងផ្នែកតម្រូវការ តាមរយៈការលើកកម្ពស់ការផ្តល់សិទ្ធិអំណាចផ្នែកច្បាប់ដល់កុមារ ស្ត្រី និងគ្រួសារ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌ និងធ្វើឱ្យមានយុត្តិធម៌ចំពោះការរំលោភបំពានសិទ្ធិរបស់គេ។

## គ. ប្រព័ន្ធដែលកុមារអាចរាយការណ៍បាន

៩. ចាប់តាំងពីឆ្នាំ២០០៤មក គ្រប់ឃុំសង្កាត់ទាំងអស់នៅក្នុងប្រទេស បានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ ដែលជាយន្តការនៅមូលដ្ឋានមួយ ដែលកុមារអាចរាយការណ៍ពីបញ្ហា ឬបណ្តឹងតវ៉ារបស់ខ្លួន។ គណៈកម្មាធិការ

ទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ បានបើកឱ្យមានការចូលរួមពីតំណាងកុមារក្នុងការពិភាក្សា ចែករំលែក និងទាមទារសិទ្ធិរបស់ពួកគេ។ ជាងនេះទៅទៀត រដ្ឋាភិបាល ដោយអនុលោមតាមដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ យន្តការការពារកុមារ ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល/អង្គការអន្តរជាតិ កំពុងអនុវត្តជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ នៅគ្រប់កម្រិតទាំងអស់។

១០. មានប៉ុស្តិ៍រដ្ឋបាលនៅគ្រប់ឃុំសង្កាត់ទាំងអស់ផងដែរ ដែលអាចឱ្យកុមាររាយការណ៍ពីការរំលោភបំពានដែលកុមារជួបប្រទះ ឬការរំលោភបំពានសិទ្ធិរបស់ពួកគេ។ នាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន ដែលស្ថិតក្រោមក្រសួងមហាផ្ទៃបានដំណើរការបណ្តាញទូរស័ព្ទពិសេសប្រចាំការ២៤ម៉ោង (ជាភាសាខ្មែរ និងអង់គ្លេស) ដែលកុមារ និងប្រជាជនគ្រប់រូបអាចរាយការណ៍ពីបញ្ហាទាក់ទងនឹងកុមារ ជាពិសេសការជួញដូរកុមារ។ កុមារក៏អាចប្រើប្រាស់សេវាបណ្តាញទូរស័ព្ទជំនួយកុមារ២៤ម៉ោងលើ២៤ម៉ោង ពេញមួយសប្តាហ៍ ដែលគ្រប់គ្រងដោយអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។ គ្រាន់តែក្នុងឆ្នាំ២០១២ មានកុមារ និងយុវជនចំនួន៥៣.៤៣៥នាក់ បានធ្វើទំនាក់ទំនង និងទទួលប្រឹក្សាយោបល់ និងការណែនាំតាមរយៈបណ្តាញទូរស័ព្ទជំនួយកុមារ។

១១. ក្នុងឆ្នាំ២០០៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងក្នុងឆ្នាំ២០០៨ បានចេញប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារ នៅតាមសហគមន៍។ បទដ្ឋានអប្បបរមាទាំងអស់ប្រគល់អំណាចដល់មជ្ឈមណ្ឌល/អ្នកផ្តល់ការថែទាំកុមារ ឱ្យបង្កើតយន្តការបណ្តឹងសម្រាប់កុមារក្នុងការថែទាំជំនួស ដើម្បីរាយការណ៍ពីបណ្តឹងតវ៉ារបស់ពួកគេ និងដើម្បីប្រាកដថា កុមារទាំងអស់បានយល់ដឹងពីសិទ្ធិ និងនីតិវិធីក្នុងការដាក់ពាក្យបណ្តឹងរបស់ពួកគេ។

១២. ច្បាប់ស្តីពីពន្ធនាគារតម្រូវឱ្យគ្រប់មណ្ឌលឃុំឃាំងទាំងអស់ ត្រូវរៀបចំនីតិវិធីបណ្តឹងតាមរយៈនេះ ជនជាប់ឃុំជាកុមារអាចដាក់បណ្តឹងរបស់ខ្លួន ដោយសម្ងាត់បាន។ ប្រអប់ទទួលពាក្យបណ្តឹងមាននៅក្នុងមណ្ឌលឃុំឃាំងចំនួន២៧ នៅទូទាំងប្រទេស ដើម្បីទទួលបានបណ្តឹងតវ៉ាពីអ្នកជាប់ឃុំឃាំង និងក្រុមគ្រួសាររបស់ពួកគេ។

១៣. ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនីតិវិធីបណ្តឹង/រាយការណ៍សម្រាប់សិស្សនៅតាមសាលារៀន ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការអប់រំ និងគោលនយោបាយជាតិស្តីពីសាលាកុមារមេត្រី។ នីតិវិធីនេះ បង្កលក្ខណៈឱ្យសិស្ស និងឪពុក

ម្តាយសិស្សអាចរាយការណ៍ពីបញ្ហា ដែលប៉ះពាល់ដល់កុមារនៅតាមសាលារៀន និងបញ្ហាទាក់ទងទៅនឹងការអប់រំរបស់កុមារ។

## ឃ. សិទ្ធិប្តឹងតាមផ្លូវច្បាប់ សមត្ថភាពផ្លូវច្បាប់ និងតំណាងផ្លូវច្បាប់សម្រាប់អនីតិជន ដែលស្ថិតនៅក្រោមច្បាប់

១៤. បទប្បញ្ញត្តិនានា ដែលស្ថិតនៅក្រោមច្បាប់កម្ពុជា អនុញ្ញាតឱ្យអនីតិជន[១]/កុមារមានសិទ្ធិប្តឹងតាមផ្លូវច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ ស្នើសុំឱ្យមានសមត្ថភាពផ្លូវច្បាប់ និងមានតំណាងផ្លូវច្បាប់។ យោងតាមមាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ និងប្រាប់ពីបទល្មើសដែលត្រូវបានចោទប្រកាន់។ ចៅក្រមត្រូវប្រាប់ជនត្រូវចោទពីសិទ្ធិក្នុងការមិនឆ្លើយតប ប៉ុន្តែប្រសិនបើជនត្រូវចោទចង់រាយការណ៍ ចៅក្រមត្រូវកត់ត្រាសេចក្តីរាយការណ៍នោះភ្លាម។ ជនត្រូវចោទជាអនីតិជន ត្រូវតែមានមេធាវីអមជានិច្ច។ ប្រសិនបើជនត្រូវចោទមិនបានជ្រើសរើសមេធាវីទេ តុលាការត្រូវតែចាត់តាំងមេធាវី។ មាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ជាក់ថា ចៅក្រមស៊ើបសួរដែលឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងសុំឱ្យជនត្រូវចោទមានយោបល់។ ប្រសិនបើជនត្រូវចោទមានមេធាវី មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនដល់ជនត្រូវចោទ។ មាត្រា៣៦៥ និងមាត្រា៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យពិរុទ្ធជនអាចប្តឹងសារទុក្ខ ចំពោះសេចក្តីសម្រេចរបស់តុលាការបាន។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ប៉ុន្តែមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិពីពិរុទ្ធជនឱ្យធ្វើសកម្មភាព។ ពិរុទ្ធជនដែលជាអនីតិជនអាចត្រូវបានតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល ហើយក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ រួមសេចក្តីមក អនីតិជនមានមធ្យោបាយ ដើម្បីជំទាស់នៅក្នុងរឿងក្តីតាមផ្លូវច្បាប់ តាមរយៈសមត្ថភាពផ្លូវច្បាប់ ឬតាមរយៈតំណាងផ្នែកច្បាប់របស់ពួកគេ។

១៥. ក្នុងករណីទំនាស់ផលប្រយោជន៍ជាមួយនឹងអ្នកតំណាងផ្លូវច្បាប់ អនីតិជនអាចស្នើសុំតំណាងថ្មីមួយរូប ស្ថិតក្រោមមាត្រា៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថា៖

- ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំបានប្រតិបត្តិនូវសិទ្ធិតំណាងនោះ បុគ្គលដែលមាន

[១] មាត្រា១៦ នៃក្រមរដ្ឋប្បវេណី ចែងថា ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ខណៈដែលមាត្រា១៨ ចែងថា សកម្មភាពដែលអនីតិជនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាល អាចលុបចោលបាន។

បំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គល ដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការដែលបានទទួលបណ្តឹង ឱ្យជ្រើសរើសអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ដំបូងថា ការខូចខាតអាចនឹងកើតឡើង ដោយសារការយឺតយ៉ាវនោះ

- តុលាការអាចផ្លាស់ប្តូរអ្នកតំណាងពិសេសនៅពេលណាក៏បាន
- ការសម្រេចសេចក្តីអំពីការជ្រើសតាំង ឬការផ្លាស់ប្តូរអ្នកតំណាងពិសេសនឹងត្រូវបានជូនដំណឹងឱ្យអ្នកតំណាងពិសេសផងដែរ
- អ្នកតំណាងពិសេសត្រូវមានការប្រគល់សិទ្ធិ ដូចអ្នកអាណាព្យាបាល ដើម្បីធ្វើសកម្មភាពបណ្តឹង។

## ខ. ការចូលរួមរបស់កុមារក្នុងដំណើរការយុត្តិធម៌

១៦. អនីតិជន និងកុមារអាចចូលរួមក្នុងដំណើរការយុត្តិធម៌ និងមានសិទ្ធិបញ្ចេញមតិរបស់ខ្លួន។ អនីតិជនត្រូវបានចាត់ទុកថា ជានីតិបុគ្គលដែលមានសិទ្ធិចូលរួមក្នុងដំណើការយុត្តិធម៌។ មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមាត្រា៦(១) ចែងថា បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន។ ស្ថិតក្រោមមាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បណ្តឹងរដ្ឋប្បវេណីមានបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់នានា ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ហើយជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការ ចំពោះវិវាទរដ្ឋប្បវេណី។ មាត្រា៣២ នៃក្រមរដ្ឋប្បវេណី ចែងថា៖

- បុគ្គលដែលអាចមានសិទ្ធិ និងករណីកិច្ច តាមបញ្ញត្តិនៃច្បាប់ អាចជាដើមចោទ ឬចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណី
- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង អាចដាក់ពាក្យបណ្តឹងដោយខ្លួនឯង ដោយតាំងខ្លួនជាដើមចោទ ការពារខ្លួនចំពោះបណ្តឹងដោយតាំងខ្លួនជាចុងចម្លើយ ឬចូលរួមក្នុងការធ្វើសកម្មភាពបណ្តឹង
- អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើសកម្មភាពបណ្តឹងបានលុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ។

## គ. ជំនួយផ្លូវច្បាប់សម្រាប់កុមារ

១៧. អនុលោមតាមមាត្រា១៦ និងមាត្រា៣២(៣) នៃក្រមនីតិវិធីរដ្ឋប្បវេណី សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជនត្រូវបានកម្រិត ហើយអនីតិជនអាចធ្វើសកម្មភាពបណ្ដឹងបាន លុះត្រាតែតាមរយៈអ្នកតំណាងស្របច្បាប់។ ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលអនីតិជន/កុមារអាចប្រើប្រាស់ទាំងតំណាងស្របច្បាប់ និងទាំងជំនួយផ្នែកច្បាប់ក្នុងករណីចាំបាច់។ ក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ជនត្រូវចោទជាអនីតិជនតែងតែត្រូវការជំនួយ នៅពេលបង្ហាញខ្លួននៅចំពោះមុខចៅក្រម។ ប្រសិនបើជនត្រូវចោទជាអនីតិជនមិនត្រូវបានតំណាងនៅក្នុងតុលាការទេ គេចាត់ទុកថា ជាការខុសឆ្គងរបស់តុលាការ។

១៨. គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសង្គមស៊ីវិល បានគាំទ្រដល់ដំណើរការរៀបចំគោលនយោបាយជាតិជំនួយផ្នែកច្បាប់ និងការផ្ដល់ជំនួយផ្នែកច្បាប់ និងសេវាសង្គមដល់កុមារដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ចំនួន១០០នាក់រៀងរាល់ឆ្នាំ។ សេវាតំណាងផ្នែកច្បាប់ត្រូវបានពង្រឹងតាមរយៈការបណ្ដុះបណ្ដាលសិទ្ធិកុមារ យុត្តិធម៌អនីតិជន និងច្បាប់និងនីតិវិធីដែលពាក់ព័ន្ធនានា។

## ឆ. ជម្រើសចំពោះនីតិវិធីរឿងក្ដីសម្រាប់កុមារ

១៩. មាត្រា១៩ នៃក្រមព្រហ្មទណ្ឌចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬប្រសិនបើបុគ្គលិកលក្ខណៈ របស់អនីតិជនតម្រូវ។ នេះមានន័យថា កុមារអាយុក្រោម១៤ឆ្នាំ ដែលប្រព្រឹត្តបទល្មើស គឺមិនមែនជាកម្មវត្ថុនៃបណ្ដឹងផ្លូវច្បាប់ទេ។ មាត្រា៩៦(១១) និង២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនត្រូវបានឃាត់ខ្លួន ឬឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចបញ្ជូនអនីតិជនជាបណ្ដោះអាសន្នទៅអ្នកអាណាព្យាបាល ឬមជ្ឈមណ្ឌលអប់រំថែទាំ ដោយរង់ចាំការសម្រេចពីតុលាការ។

២០. ជម្រើសផ្សេងទៀតក៏អាចប្រើបានដែរ ចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស មានជាអាទិ៍៖ (១)ការប្រគល់អនីតិជនទៅឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល អ្នកមើលថែទាំ ឬជនដែលអាចជឿទុកចិត្តបានដទៃទៀត តាមការចាំបាច់ ឬ (២)ប្រគល់អនីតិជនទៅមណ្ឌលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការថែទាំកុមារ មន្ទីរពេទ្យ មណ្ឌលដែលមានជំនាញឯកទេស ឬដាក់អនីតិជនឱ្យស្ថិតក្រោមការការពារពីតុលាការ អាស្រ័យទៅតាមកាលៈទេសៈ។ តាមរយៈគោលការណ៍ច្បាប់ តុលារការក៏

អាចមានជម្រើសផ្សេងទៀត ជៀសជាងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន ឧទាហរណ៍ តាមរយៈការងារសហគមន៍ ការស្ដីបន្ទោស និងការសាកល្បង។

## ជ. លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់កុមារ

២១. ប្រទេសកម្ពុជាមិនមានច្បាប់ដោយឡែក ដែលចែងពីកិច្ចការពារជនរងគ្រោះជាកុមារទេ ប៉ុន្តែបទប្បញ្ញត្តិដែលមានស្រាប់ ជួយឱ្យជនគ្រោះជាកុមារអាចស្វែងរកយុត្តិធម៌តាមរយៈការប្ដឹងទៅស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមរយៈបណ្ដឹង ជនរងគ្រោះជាកុមារនឹងទទួលបានយុត្តិធម៌តាមមធ្យោបាយចំនួន២៖ (១)អ្នកប្រព្រឹត្តបទល្មើសនឹងត្រូវបានចោទប្រកាន់ ដូច្នេះស្ថាប័នអយ្យការ អាចស្នើឱ្យតុលាការដាក់ទោសឱ្យបានត្រឹមត្រូវលើអ្នកប្រព្រឹត្តបទល្មើស (២) ព្យសនកម្មត្រូវបានជួសជុលតាមរយៈបណ្ដឹងរដ្ឋប្បវេណី ដែលប្ដឹងដោយជនរងគ្រោះ បន្ថែមពីលើបណ្ដឹងអាជ្ញា ដែលបានធ្វើឡើងដោយព្រះរាជអាជ្ញា។ បណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអនុវត្តដោយជនរងគ្រោះនៃបទល្មើស។ ប៉ុន្តែដើម្បីឱ្យមានការជួសជុលបាន ព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់នៃបទល្មើស ជា ព្យសនកម្មផ្ទាល់ខ្លួន បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន។ ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ រូបកាយ និងផ្លូវចិត្ត។ ជនរងគ្រោះត្រូវដាក់បណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ ដើម្បីទាមទារឱ្យមានការជួសជុលព្យសនកម្ម ដែលបានកើតឡើង។ ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជំងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឱ្យមានសភាពដូចដើមវិញនូវទ្រព្យសម្បត្តិដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត។ សំណងជំងឺចិត្តត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្ម (មាត្រា១៤)។ មាត្រា៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា កាលណាដើមបណ្ដឹងរដ្ឋប្បវេណីមិនបានទទួលសំណង ឬជំងឺចិត្តពីពិរុទ្ធជន ឬចុងចោទរដ្ឋប្បវេណីទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំឱ្យសងបាន។

២២. ប្រកាសស្ដីពីការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការ និងបន្ទប់សវនាការភ្ជាប់បណ្ដាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារ/ជនរងគ្រោះ និងសាក្សីដែលងាយរងគ្រោះ ត្រូវបានចេញដោយក្រសួងយុត្តិធម៌នៅឆ្នាំ២០០៨ ដោយបន្ថែមការដំឡើងរបាំងសវនាការក្នុងតុលាការគ្រប់រាជធានីខេត្តទាំងអស់ និងការតម្លើងឧបករណ៍សម្រាប់ធ្វើសន្និសីទតាមរយៈវីដេអូនៅក្នុងតុលាការខេត្តចំនួន៥ ដែលជាខេត្តអាទិភាព។ ប្រកាស និងឧបករណ៍កុមារមេត្រី ជាមធ្យោបាយដើម្បីជួយឱ្យជនរងគ្រោះជាកុមារ និងសាក្សីអាចផ្ដល់សក្ខីកម្មឱ្យកាន់តែមានលក្ខណៈសុក្រឹត្យ ក្នុងបរិយាកាសមិនមានការបង្ខិតបង្ខំ។

## ឈ. ចំណេះដឹងរបស់កុមារអំពីសិទ្ធិរបស់ខ្លួន

២៣. រាជរដ្ឋាភិបាលកម្ពុជា លើកកម្ពស់ការអនុវត្តសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារៈ សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម។ អាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ ជាពិសេសគណៈកម្មធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយទាក់ទងទៅនឹងសិទ្ធិកុមារ។ ក្រសួង ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន បានលើកកម្ពស់ការយល់ដឹងយ៉ាងទូលំទូលាយស្តីពីសិទ្ធិកុមារ តាមរយៈ ទូរទស្សន៍ វិទ្យុ កាសែត ផ្ទាំងរូបភាព បដា ការបណ្តុះបណ្តាល ការអប់រំសហគមន៍ ។ល។ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជ្រាបសិទ្ធិកុមារទៅក្នុងកម្មវិធីសិក្សាសម្រាប់ការអប់រំនៅថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងាររដ្ឋាភិបាល ដើម្បីផ្តល់ការបណ្តុះបណ្តាលសិទ្ធិកុមារដល់កុមារនៅតាមសាលារៀន និងសហគមន៍។

## ញ. ការបណ្តុះបណ្តាលមន្ត្រីនគរបាល និងអ្នកជំនាញផ្នែកច្បាប់អំពីសិទ្ធិកុមារ

២៤. ស្ថាប័នសាធារណៈ និងអង្គការសង្គមស៊ីវិល បានរួមគ្នារៀបចំ បោះពុម្ព និងចែកចាយសៀវភៅ/កូនសៀវភៅបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ ជាពិសេសដើម្បីអប់រំនគរបាលយុត្តិធម៌ និងអ្នកជំនាញផ្នែកច្បាប់។ ឧទាហរណ៍ ក្រសួងមហាផ្ទៃបានប្រើសៀវភៅបណ្តុះបណ្តាលសិទ្ធិកុមារទាំងនេះ ដើម្បីបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងរាជធានីខេត្តទាំង២៤។ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រឹត្យការវិជ្ជាជីវៈមេធាវីបានបញ្ចូលឧបករណ៍បណ្តុះបណ្តាលទាំងនេះទៅក្នុងកម្មវិធីសិក្សាសម្រាប់និស្សិតមេធាវី និងមេធាវីប្រកបវិជ្ជាជីវៈ។ រាជបណ្ឌិត្យសភាវិជ្ជាជីវៈច្បាប់ ក៏បានបញ្ចូលសិទ្ធិកុមារទៅក្នុងកម្មវិធីសិក្សាសម្រាប់សិស្សចៅក្រម និងចៅក្រមប្រកបវិជ្ជាជីវៈផងដែរ។ អង្គការជំនួយផ្នែកច្បាប់កម្ពុជា បានបណ្តុះបណ្តាលនគរបាលយុត្តិធម៌ (នគរបាល និងកងរាជអាវុធហត្ថ) នៅក្នុងខេត្តសៀមរាប និងបន្ទាយមានជ័យអំពីសិទ្ធិកុមារសិទ្ធិរបស់កុមារដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ និងច្បាប់ និងគោលនយោបាយពាក់ព័ន្ធទៅនឹងកុមារដទៃទៀតក្នុងឆ្នាំ២០១១ និង២០១២ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការសង្គ្រោះកុមារ និងសហភាពអឺរ៉ុប។ មន្ត្រីអនុវត្តច្បាប់នៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានបណ្តុះបណ្តាលជំនាញពាក់ព័ន្ធទៅនឹងការធ្វើសម្ភាសកុមារ និងបច្ចេកទេសកុមារមេត្រី ដើម្បីដោះស្រាយកុមារដែលជាជនល្មើស ជនរងគ្រោះ ឬជាសាក្សី។

២៥. ក្នុងចំណោមកិច្ចខិតខំប្រឹងប្រែងជាច្រើនគួរឱ្យកត់សម្គាល់ ខ្សែវីដេអូណែនាំចំនួនពីរស្តីពីប្រព័ន្ធយុត្តិធម៌សម្រាប់ជនរងគ្រោះ និងសាក្សីជាកុមារ និងសម្រាប់កុមារដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ ក្រោមចំណងជើងថា "តាមរយៈក្រសែភ្នែករបស់កុមារៈ ការណែនាំស្តីពីប្រព័ន្ធយុត្តិធម៌" ត្រូវបានបញ្ចប់នៅឆ្នាំ២០០៩ និងត្រូវបានផ្សព្វផ្សាយ ដោយក្រុមការងារយុត្តិធម៌កុមារ ដល់អ្នកពាក់ព័ន្ធ ដោយមានការណែនាំពីអ្នកសម្របសម្រួល។ ខ្សែវីដេអូគឺជាមធ្យោបាយ ដើម្បីជួយអ្នកធ្វើការងារសង្គមមេធាវី និងមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌដទៃទៀតក្នុងការរៀបចំកុមារឱ្យតតាំងជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងត្រូវបានប្រើដោយក្រុមការងារយុត្តិធម៌កុមារ ដែលជាឧបករណ៍ផ្សព្វផ្សាយ ក្នុងកិច្ចប្រជុំសម្របសម្រួលរវាងមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ។

## ង. ការអប់រំ បណ្តុះបណ្តាលអំពីសិទ្ធិកុមារដល់ឪពុកម្តាយ គ្រូបង្រៀន ប្រជាជន និងអំពីអ្វីដែលពួកគេអាចទទួលបានយុត្តិធម៌

២៦. រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដោយផ្ទាល់ និងដោយប្រយោល ដើម្បីលើកម្ពស់សិទ្ធិកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)[២] បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារជាច្រើន ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់នៃក្រសួងពាក់ព័ន្ធ។ ក្រសួងព័ត៌មាន បានរៀបចំរឿងខ្លី/ឯកសារស្តីពីសិទ្ធិកុមារ និងត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ស្តីពីបញ្ហាសិទ្ធិកុមារ។ ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ការបណ្តុះបណ្តាលជាប្រចាំស្តីពីអនុសញ្ញាសិទ្ធិកុមារនៃអង្គការសហប្រជាជាតិដល់នាយក នាយករងសាលា គ្រូបង្រៀន និងសិស្សនៅថ្នាក់បឋមសិក្សា និងវិទ្យាល័យនៅទូទាំងប្រទេស។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងាររដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយអនុសញ្ញាសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ និងរៀបចំព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ដល់និស្សិតនៅសាលាគរុកោសល្យចំនួន៧ គ្រូបង្រៀន និងសិស្សនៅតាមសាលាបឋមសិក្សា និងវិទ្យាល័យជាច្រើន និងក្រុមឪពុកម្តាយនៅតាមសហគមន៍។

២៧. ដោយមានកិច្ចគាំទ្រពីអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍន៍នានា ចៅក្រម ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ អ្នកធ្វើការងារសង្គម និងមន្ត្រីនៃមណ្ឌលកែប្រែជាង១០០០នាក់ ត្រូវបានបណ្តុះបណ្តាលស្តីពីគោលការណ៍ និងបទដ្ឋានអន្តរជាតិ ក៏ដូចជាច្បាប់

[២] បង្កើតឡើងនៅឆ្នាំ១៩៩៥ ក.ជ.ក. ដើរតួនាទីជាភ្នាក់ងារជំនាញរបស់រាជរដ្ឋាភិបាលក្នុងការណែនាំ សម្របសម្រួល ពិនិត្យតាមដាន និងរាយការណ៍ពីការអនុវត្តសកម្មភាពសិទ្ធិកុមារ និងធានាថា បញ្ហាកុមារត្រូវបានផ្តល់អាទិភាពក្នុងផែនការអភិវឌ្ឍន៍ជាតិ។

ជាតិ ក្របខ័ណ្ឌកំណត់ដោយច្បាប់ និងឧបករណ៍នានាស្តីពីយុត្តិធម៌កុមារ។ ចៅក្រម និងព្រះរាជអាជ្ញា បានបង្ហាញនូវការគោរពច្បាប់កាន់តែច្រើនឡើងៗ និងនីតិវិធីពាក់ព័ន្ធទៅនឹងកុមារ និងការយល់ដឹងពីតម្រូវការរបស់ពួកគេ។ អ្នកធ្វើការងារសង្គម នៅក្នុងខេត្តអាទិភាព ក៏បានបង្ហាញពីការធ្វើឱ្យប្រសើរឡើងនូវជំនាញ ក្នុងការគ្រប់គ្រងករណី និងការធ្វើសមាហរណកម្មកុមារ ដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ និងកិច្ចសហការកាន់តែរឹងមាំជាមួយអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីពន្ធនាគារ/មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម។

២៨. សៀវភៅបណ្តុះបណ្តាលស្តីពី "កុមារដែលស្ថិតនៅក្នុងការឃុំខ្លួន" ត្រូវបានរៀបចំ និងសាកល្បងកាលពីឆ្នាំ២០០៨។ ក្នុងឆ្នាំ២០១០ មន្ត្រី/អនុរក្សពន្ធនាគារចំនួន៧៨នាក់ មកពី ២៤រាជធានីខេត្ត ត្រូវបានបណ្តុះបណ្តាលពីសិទ្ធិកុមារ ការអភិវឌ្ឍកុមារ និងយុត្តិធម៌កុមារ ដោយអគ្គលេខាធិការដ្ឋានពន្ធនាគារ។

## ឋ. មធ្យោបាយដោះស្រាយដែលមានប្រសិទ្ធភាពសម្រាប់កុមារ

២៩. ក្រោមការជួយឧបត្ថម្ភពីអង្គការយូនីសេហ្វ កម្មវិធី និង យន្តការបង្ការ និងបង្វែរអនីតិជនប្រព្រឹត្តបទល្មើសនៅតាមមូលដ្ឋាន ត្រូវបានបង្កើតឡើងក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។ អនុគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ទទួលបន្ទុកការបង្ការអនីតិជនប្រព្រឹត្តបទល្មើស ត្រូវបានបង្កើតឡើង ដើម្បីកំណត់កុមារដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងកុមារដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ ផ្តល់អនុសាសន៍ស្តីពីជម្រើសបង្វែរ និងផ្តល់ដំណោះស្រាយនៅតាមមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារដែលជាគោលដៅ។ សមាជិកអនុគណៈកម្មាធិការបានចូលរួមកាន់តែច្រើនឡើង ក្នុងការកំណត់ជម្រើស និងដំណោះស្រាយធ្វើសមាហរណ្ណកម្មសម្រាប់កុមារដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ និងបានស្វែងរកសេវាគាំទ្រ និងសេវាបញ្ជូនសម្រាប់កុមារទាំងនោះ។

## ឌ. វិធានការជាក់លាក់ជាពិសេសដើម្បីជួយក្រុមកុមារដែលងាយរងគ្រោះឱ្យទទួលបានយុត្តិធម៌ (មានបញ្ជាក់ខាងលើរួចហើយ)